# «កិច្ចប្រជុំកំពូលអាស៊ានពិសេសស្ដីពីកូវីដ-១៩
# និងក្តីសង្ឃឹមរបស់ប្រជាជាតិអាស៊ានអំពីការប្រយុទ្ធប្រឆាំង
# នឹងការរីករាលដាលជំងឺកូវីដ-១៩»

ដោយៈ បណ្ឌិត ឈត ប៊ុនថង, វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិកម្ពុជា




ក្រោយពីពិភពលោកទាំងមូល រួមទាំងតំបន់អាស៊ានដែរ កំពុងរងការវាយប្រហារពីមេរោគឆ្លងកូវីដ-១៩ ប្រទេសអាស៊ានបានលើកប្រធានបទទាក់ទងនឹងមេរោគឆ្លងជំងឺកូវីដ-១៩ មកបញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំកំពូលពិសេសរបស់ខ្លួនផង។ កិច្ចប្រជុំនេះធ្វើឡើងតាមរយៈប្រព័ន្ធវីដេអូ ( Video Conference ) កាលពីនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ ដែលមានលោក ង្វៀន សួនហ្វុក នាយករដ្ឋមន្ត្រីវៀតណាម ជាប្រធានអង្គប្រជុំក្នុងឋានៈជាប្រធានប្តូរវេនរបស់អាស៊ាន។ ក្រៅពីកិច្ចប្រជុំកំពូលអាស៊ានពិសេស ក៏មានកិច្ចប្រជុំកំពូលអាស៊ានបូកបីពិសេស ដែលមានចិន ជប៉ុន និងកូរ៉េខាងត្បូង ចូលរួមផងដែរ។

នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានពិសេស និងកិច្ចប្រជុំកំពូលអាស៊ានបូកបីពិសេស ស្តីពីកូវីដ-១៩ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងសុន្ទរកថាដ៏មានអត្ថន័យចំនួន២ ស្តីពីផលប៉ះពាល់នៃ

ជំងឺកូវីដ-១៩ ទៅលើការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងកំណើនសេដ្ឋកិច្ចពិភពលោក ព្រមទាំងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ទៅលើសន្តិសុខ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចការសង្គមជារួម ដែលទាមទារកិច្ចប្រឹងប្រែងរួមគ្នាជាអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងនៃជំងឺកូវីដ-១៩នេះ។

ជារួម កិច្ចប្រជុំកំពូលពិសេសទាំងពីរនេះ គឺជាព្រឹត្តិការណ៍ដ៏សំខាន់បន្ថែមទៀតដែលឆ្លុះបញ្ចាំងអំពីការរួបរួមរបស់អាស៊ានតាមរយៈសកម្មភាពរួមនៃការជួយគ្នាទៅវិញទៅមក ការលើកកម្ពស់ការឆ្លើយតបដោយធ្វើសកម្មភាពយ៉ាងឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាពនៅក្នុងការគ្រប់គ្រងជំងឺ និងការពង្រឹងភាពរឹងមាំរបស់តំបន់ ស្របពេលជាមួយការត្រៀមលក្ខណៈរួចជាស្រេច ក្នុងការរិះរកកិច្ចសហប្រតិបត្តិការជាមួយដៃគូខាងក្រៅរបស់អាស៊ាន និងសហគមន៍អន្តរជាតិ ក្នុងការលើកកម្ពស់ការត្រៀមខ្លួនជាស្រេច និងវិធានការឆ្លើយតប ដើម្បីកាត់បន្ថយនិងលុបបំបាត់ផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩។

បើយោងទៅតាមសេចក្តីប្រកាសរួមនៃកិច្ចប្រជុំនេះដែលមានកម្រាស់ជាង៣ទំព័រនោះ ប្រជាជាតិអាស៊ានគួរតែទទួលបានក្តីសង្ឃឹម ភាពកក់ក្តៅ និងភាពធូរស្រាលពីការវាយប្រហារនិងផលប៉ះពាល់ដែលបង្កឡើងដោយមេរោគឆ្លងជំងឺកូវីដ១៩។

ប៉ុន្តែ បើយោងតាមបទពិសោធន៍ គោលការណ៍ និងចំណាត់ការជាក់ស្តែងរបស់អាស៊ានកន្លងមក ប្រជាជាតិអាស៊ាន នឹងមិនទទួលបានអ្វីជាដុំកំភួនទេ។ ពីព្រោះអាស៊ាន គឺអង្គការតំបន់មួយមានទម្រង់ជាអន្តររដ្ឋាភិបាល ដែលមានធម្មនុញ្ញ មានចក្ខុវិស័យ គោលការណ៍ ទស្សនវិស័យ និងសេចក្តីប្រកាសរួមជាច្រើនរាប់មិនអស់ចេញពីកិច្ចប្រជុំដ៏សន្ធឹកសន្ធាប់របស់ខ្លួន។ ប៉ុន្តែ អង្គការនេះ ត្រូវបានគេវាយតម្លៃថា ជាអង្គការមិនសូវមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងការដោះស្រាយបញ្ហាក្នុងតំបន់របស់ខ្លួន ដោយសារតែអង្គការនេះគ្មានយន្តការនិងអំណាចចាប់បង្ខំឱ្យរដ្ឋជាសមាជិករបស់ខ្លួនឱ្យគោរពតាមធម្មនុញ្ញ ចក្ខុវិស័យ គោលការណ៍ ទស្សនវិស័យ និងសេចក្តីប្រកាសរួមរបស់ខ្លួន ដែលបញ្ហានេះត្រូវបានគេមើលឃើញថា បណ្តាលមកពីរបាំងនៃគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃរដ្ឋសមាជិកនីមួយៗ។

មិនតែប៉ុណ្ណោះ ពេលខ្លះទៀត សូម្បីតែសេចក្តីប្រកាសរួមឬដំណោះស្រាយរួមពាក់ព័ន្ធនឹងការការពារផលប្រយោជន៍នៃសមាជិករបស់ខ្លួនពេលមានទំនាស់ជាមួយប្រទេសក្រៅតំបន់ ក៏មិនអាចសម្រេចបានដែរ ដោយសារតែពិបាករកសំឡេងឯកភាព១០០% តាមគោលការណ៍កុងសង់ស៊ីសរបស់ខ្លួន។ ក្រៅពីនេះ រដ្ឋជាសមាជិកអាស៊ានភាគច្រើន ត្រូវបានគេមើលឃើញថា តែងតែតម្កល់ផលប្រយោជន៍ផ្ទាល់ខ្លួនធំជាងផលប្រយោជន៍រួមរបស់តំបន់។

ហេតុនេះ យោងលើបទពិសោធន៍និងចំណាត់ការកន្លងមក និងយោងលើគោលការណ៍របស់អាស៊ាន យើងជាប្រជាជាតិអាស៊ាន មិនសង្ឃឹមថា ថ្នាក់ដឹកនាំនៃប្រទេសអាស៊ាននឹងយកស្មារតីនៃសេចក្តីប្រកាសរួមដែលទើបតែចេញកាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ ដោយកិច្ចប្រជុំកំពូលអាស៊ានពិសេសស្តីពី កូវីដ-១៩ មកប្រើសម្រាប់ការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺកូវីដ-១៩ឡើយ។ កន្លងមកអាស៊ានក៏ធ្លាប់បានបង្កើតចក្ខុវិស័យ ទស្សនវិស័យ គោលការណ៍ ព្រមទាំងបានចេញសេចក្តីប្រកាសរួមជាច្រើន ប៉ុន្តែអាស៊ានមិនមានយន្តការតាមដានលើការអនុវត្ត និងក៏គ្មានអំណាចចាប់បង្ខំឱ្យសមាជិករបស់ខ្លួនឱ្យអនុវត្តស្មារតីនៃសេចក្តីសម្រេចនានារបស់ខ្លួនដែរ។

អាស៊ាន ហាក់ដូចជាអង្គការសម្រាប់ជជែកគ្នា ប៉ុន្តែចំពោះការជួយគ្នាជាក់ស្តែងវិញ ទើបតែធ្វើបានតិចតួចនៅឡើយ។ មានភ័ស្តុតាងជាច្រើនទៀតដែលអាចបញ្ជាក់បាន ដូចជាបញ្ហាជម្លោះព្រំដែនរវាងកម្ពុជានិងថៃ, បញ្ហាសមុទ្រចិនខាងត្បូងដែលពាក់ព័ន្ធនឹងសមាជិកអាស៊ានមួយចំនួន, រដ្ឋប្រហារយោធានៅប្រទេសថៃ និងការរំលោភសិទ្ធិមនុស្សនៅប្រទេសមីយ៉ាន់ម៉ា ជាដើម។ ជាពិសេស ពេលដែលជំងឺកូវីដ-១៩ ផ្ទុះឡើងភ្លាមៗ ប្រទេសនីមួយៗបានគិតខិតខំដោះស្រាយតែរៀងៗខ្លួនដោយមិនបានជួយគ្នាទេ។ មិនតែប៉ុណ្ណោះមានករណីខ្លះ បានអនុញ្ញាតឱ្យអ្នកដែលគេដឹងថាបានឆ្លងជំងឺកូវីដ-១៩ហើយ ឆ្លងដែនចូលទៅប្រទេសជាសមាជិកអាស៊ានដូចគ្នា ដូចជា ករណីជនជាតិឥណ្ឌូនេស៊ីពីរនាក់ ដែលប្រទេសថៃបានធ្វើតេស្តដឹងថាមានជំងឺកូវីដ-១៩វិជ្ជមាន នៅតែអនុញ្ញាតឱ្យឆ្លងដែលចូលមកកម្ពុជាជាដើម។ ទាំងអស់នេះសុទ្ធតែជាបញ្ហាដែលអង្គការតំបន់មួយនេះមិនបានជួយដោះស្រាយអ្វីទាល់តែសោះ។ អាស៊ាន ហាក់ដូចជាអង្គការដែលជួយដល់អ្នកនយោបាយជាងជាងជួយដល់ប្រជាជាតិអាស៊ាន។ ហេតុនេះ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើសុខភាព ជីវភាព មុខរបរ និងអាយុជីវិតរបស់ប្រជាជាតិអាស៊ាន ប្រហែលជាអង្គការនេះមានលទ្ធភាពជួយបានតិចតួចណាស់៕